**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * * *

នៅព្រឹកថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យ **ឯកឧត្តម ទូ ជាហោ** (Du Jiahao) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាលេខាធិការគណៈកម្មាធិកាបក្សកុម្មុយនីស្តចិនខេត្តហ៊ូណាន ចូលជួបសម្តែងការគួរសមនៅទីស្តីការក្រសួង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **ឯកឧត្តម ទូ ជាហោ** ដែលបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅកម្ពុជា។ ទស្សនកិច្ចនេះ បានរួមចំណែកពង្រឹង និងពង្រីកបន្ថែមទៀតនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន ដែលត្រូវបានបង្កើតឡើងដោយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរតាំងពីសម័យមុន ហើយបន្តឈានដល់ភាពជាដៃគូរយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយនាពេលបច្ចុប្បន្នដោយមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចជាច្រើនរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន និងការរៀបចំមហាសន្និបាតពេញអង្គ នៃបក្សកុម្មុយនីស្តចិនប្រកបដោយជោគជ័យនាពេលកន្លងមកនេះ។ **ឯកឧត្តម** បានបញ្ជាក់ថា បើទោះជា កម្ពុជាមានលក្ខណៈខុសពីចិន ដោយសារកម្ពុជាមានគណបក្សជាច្រើន ក៏ប៉ុន្តែគណបក្សប្រជាជនកម្ពុជា និងគណបក្សកុម្មុយនីស្តចិន មានលក្ខណៈដូចគ្នា ត្រង់ចំនុចគណបក្សទាំងពីរផ្តោតលើផលប្រយោជន៍ប្រជាពលរដ្ឋជាចំបង។

ជាការឆ្លើយតប **ឯកឧត្តម ទូ ជាហោ** បានសម្តែងនូវអំណរគុណដល់ថ្នាក់ដឹកនាំកម្ពុជាគ្រប់លំដាប់ថ្នាក់ដែលបានទទួលស្វាគមន៍ប្រកបដោយភាពកក់ក្តៅនៅក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាពេលនេះ ហើយឯកឧត្តមបានដឹកនាំប្រតិភូមកជាច្រើន ក្នុងនោះក៏មានប្រធានក្រុមហ៊ុនធំៗមកពីខេត្តហ៊ូណាន ដើម្បីពិនិត្យសក្តានុពលផ្នែកសេដ្ឋកិច្ច និងវិនិយោគលើវិស័យជាច្រើនដូចជា ឧស្សាហកម្ម កសិកម្ម គ្រឿងយន្តកសិកម្ម និងវិស័យ ផ្សេងៗទៀត។ នៅថ្ងៃទី ១៩ វិច្ឆិកា ២០១៩នេះ នឹងមានពិធីចុះហត្ថលេខារវាងវិនិយោគិនមកពីខេត្តហ៊ូណាន និងវិនិយោគិនកម្ពុជាដែលមានទឹកប្រាក់ចំនួន ១៣០០លានដុល្លាអាមេរិក (មួយពាន់បីរយលានដុល្លារ) ។

**ឯកឧត្តម ទូ ជាហោ** ក៏បានបញ្ជាក់ដែរថា ខេត្តហ៊ូណានគឺជាខេត្តដ៏មានសក្តានុពលផ្នែកឧស្សាហកម្មកសិកម្ម និងបច្ចេកវិទ្យាមួយ ដែលជួយជំរុញកំណើនសេដ្ឋកិច្ចចិន។ ខេត្តមានផលិតផលក្នុងស្រុកសរុប(GDP) ប្រមាណ ៥៥០,០០០ លានដុល្លារ និងចំនួនប្រជាជនប្រមាណ ៧៣លាននាក់។ ថ្នាក់ដឹកនាំចិនសំខាន់ៗមួយចំនួន រួមទាំង អតីតប្រធានរដ្ឋចិន ម៉ៅ សេទុង មានស្រុកកំណើតនៅក្នុងខេត្តនេះ។

ពាក់ព័ន្ធនឹងស្ថានភាពកម្ពុជា **ឯកឧត្តម ទូ ជាហោ** បានលើកឡើងថា ទាំងឯកឧត្តម និងវិនិយោគិនចិន បានមើលឃើញកម្ពុជាមានស្ថេរភាពនយោបាយល្អ ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចដ៏ឆាប់រហ័ស ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ប្រធានគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សមានបទពិសោធន៍ដឹកនាំប្រទេសជាច្រើនឆ្នាំ។ ដូច្នេះវិនិយោគិនចិនមានទំនុកចិត្តខ្លាំងក្នុងការបណ្តាក់ទុនវិនិយោគរបស់ខ្លួនដ៏ច្រើនសន្ធឹកសន្ធាប់នៅកម្ពុជា។

នៅក្នុងឱកាសនោះ **ឯកឧត្តម ទូ ជាហោ** បានគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងមន្ត្រីរដ្ឋាភិបាលដទៃទៀត ទៅបំពេញទស្សនកិច្ចផ្លូវការទៅខេត្តហ៊ូណាន ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងខេត្ត ក៏ដូចជានៅក្នុងប្រទេសចិនទាំងមូល។

ជាការឆ្លើយតប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវសេចក្តីរីករាយស្វាគមន៍វិនិយោគិន ពីខេត្តហ៊ូណាន និងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលនាំមកនូវទុនវិនិយោគទឹកប្រាក់ចំនួន១៣០០លានដុល្លា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានទទួលយកសេចក្តីអញ្ជើញ ហើយនឹងរកពេលវេលាសមស្របណាមួយក្នុងការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅខេត្តហ៊ូណាន។ **ឯកឧត្តម** ក៏បានបញ្ជាក់ជូនឯកឧត្តម **ទូ ជាហោ** ថា ជានិច្ចកាលកម្ពុជាប្រកាន់ខ្ជាប់នយោបាយចិនតែមួយ ដោយចាត់ទុកបញ្ហាតៃវ៉ាន់ ទីបេ ស៊ិនជាង និងហុងកុង គឺជាកិច្ចការផ្ទៃក្នុងរបស់ចិន។

ឆ្លៀតឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណដល់រដ្ឋាភិបាលចិនក្នុងការផ្តល់ជំនួយគ្រប់ប្រភេទជាច្រើនដល់កម្ពុជា ដែលបានជួយអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ជាអាទិ៍ វិស័យហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខ ការពារជាតិ និងវិស័យជាច្រើនទៀត ។ ជំនួយទាំងនេះជួយអោយកម្ពុជាមានការអភិវឌ្ឍចំគោលដៅ និងរក្សាបានសុខសន្តិភាព ស្ថេរភាព ឯករាជ្យភាព និងអធិបតេយ្យភាពពេញលេញ។